## សៀវភៅអនុស្សាវរីយ៍

# ពិធីបុណ្យជ្រមុជទឹក

សូមធ្វើសៀវភៅមួយដើម្បីជួយអ្នកចងចាំពីពិធីបុណ្យជ្រមុជទឹករបស់អ្នក ។ ប្រសិនបើអ្នកមិនទាន់ទទួលបុណ្យជ្រមុជទឹក នៅឡើយទេ អ្នកធ្វើសៀវភៅរបស់អ្នកអំពីសភាពនៃពិធីបុណ្យជ្រមុជទឹក នៅពេលអ្នកជ្រមុជទឹក ។



១.
ចូរកាត់ក្រដាសជាពីរ ។ សូមដាក់ក្រដាសឲ្យច្រើនសន្លឹកប្រសិនបើអ្នកចង់បានសៀវភៅក្រាស់ ។



២.
សូមដាក់ក្រដាសត្រួតលើគ្នា ហើយបត់វាជាពីរ ។



៣.
សូមចោះរន្ធបីតាមស្នាមបត់ក្រដាសដែលបត់នោះ ។



៤.
សូមចងខ្សែអំបោះតាមរន្ធនីមួយៗ ។

### គំនិតយោបល់ខ្លះសម្រាប់សៀវភៅរបស់អ្នក

នៅពេលនេះអ្នកត្រៀមខ្លួនជាស្រេចដើម្បីបំពេញសៀវភៅរបស់អ្នកជាមួយនឹងអនុស្សាវរីយ៍នៃពិធីបុណ្យជ្រមុជទឹករបស់អ្នក ! ខាងក្រោមនេះគឺជាគំនិតមួយចំនួន ៖

- គំនូរ ឬរូបថតនៃពិធីបុណ្យជ្រមុជទឹករបស់អ្នក
- ទីបន្ទាល់របស់អ្នក
- របៀបដែលអ្នករៀបចំខ្លួនដើម្បីទទួលពិធីបុណ្យជ្រមុជទឹករបស់អ្នក
- តើនរណាជាអ្នកជ្រមុជទឹក និងធ្វើពិធីបញ្ជាក់ឲ្យអ្នក
- តើអ្នកមានអារម្មណ៍យ៉ាងណានៅពេលប្អូនបានទទួលពិធីបុណ្យជ្រមុជទឹក
- របៀបដែលអ្នកនឹងរក្សាសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់អ្នក